# មាតាបិតាក៏រាប់ផងដែរ

## ជួយកូនរបស់លោកអ្នកនៅក្នុង – ការវាស់កំដៅ និងមើលម៉ោង

ដើម្បីឲ្យកុមារអាចយល់អំពីការវាស់ យើងត្រូវការបង្ហាញប្រាប់ គេអំពីរបៀប ប្រើរង្វាស់នៅក្នុងស្ថានការណ៍ពិតៗ។ យើងក៏គួរតែលើកទឹកចិត្តឲ្យមានភាសាទាក់ទិននឹងការវាស់នោះផងដែរ ដោយនិយាយអំពី:

- របស់ទាំងឡាយដែលយើងអាចវាស់
- របស់ទាំងឡាយដែលយើងប្រើសំរាប់វាស់ ហើយក្រោយមក
- រង្វាស់ដែលយើងប្រើដើម្បីវាស់របស់ដូចជានាទី និងម៉ោង ឬដឺក្រេ។

## តើកុមាររៀនចេះវាស់កំដៅ និងមើលម៉ោងដោយបែបណា?

កុមារត្រូវការឲ្យមានឱកាសទាំងឡាយ ដើម្បីប្រៀបធៀបរបស់ពីរ ឬច្រើនដើម្បីឲ្យបានយល់អំពីការវាស់។ ដើម្បីឲ្យបានយល់អំពីកំដៅ គេត្រូវការប្រៀបធៀបរបស់ពីរមុខដើម្បីវាស់ឲ្យឃើញសារធាតុដែល "ក្តៅខ្លាំង" ឬ "ត្រជាក់ខ្លាំង"។ គេត្រូវការមើល ហើយនិយាយអំពីរបៀបដែលកំដៅអាចប៉ះពាល់ដល់របស់ទាំងឡាយ (ដូចគ្នានឹងរបៀបដែលយើងអាចវាស់កំដៅផងដែរ។ ជាដំបូងកុមារនឹងរៀនចេះអំពីពេលវេលាតាមរយៈការប្រើភាសាដូចជា *ម្សិលមិញថ្ងៃនេះ* និង *ថ្ងៃស្អែក* និងតាមរយៈការប្រៀបធៀបពេលវេលាដែលវាត្រូវការ ដើម្បីបំពេញកិច្ចការ។ *ខ្ញុំអាចទះដៃរបស់ខ្ញុំបានបីដង ក្នុងកាលដែលអ្នកបោះបាល់ឡើងទៅលើ ហើយចាប់វា។* ក្រោយមក កុមារនឹងរៀនចេះមើលម៉ោង ចេញពីម៉ោងចង្អុលប្រាប់ជាលេខ និងម៉ោងបង្ហាញប្រាប់ជាលេខ។





# មាតាបិតាក៏រាប់ផងដែរ

## តើលោកអ្នកអាចធ្វើអ្វីបានខ្លះនៅផ្ទះ?

- និយាយអំពីព្រឹត្តិការណ៍ដែលបញ្ជាក់ជាពេលវេលា។ ឧទាហរណ៍ *វានឹងត្រូវការពេលប្រហែលជាពាន់ទាទីដើម្បីចំអិន ដូច្នេះអ្នកនឹងមានពេលដើម្បីលាបបើនំប៉ុង។*
- រកប្រភេទនៃមោ៉ង ឬនាឡិកាខុសៗគ្នាដែលមាននៅក្នុងផ្ទះ។ សួរកូនរបស់លោកអ្នកថាតើមោ៉ង ឬនាឡិកាទាំងនោះចង្អុលប្រាប់ជាលេខ ឬបង្ហាញប្រាប់ជាលេខ។
- ឲ្យកូនរបស់លោកអ្នកជួយរៀបចំមោ៉ងនៅចង្ក្រានដាំស្ល ឬនាឡិការោទិ៍។
- កត់ចុះនូវព្រឹត្តិការណ៍ពិសេសនៅពីលើប្រក្រតិទិន ហើយសួរថាតើនៅចំនួនប៉ុន្មានថ្ងៃ ឬប៉ុន្មានសប្តាហ៍មុននឹងដល់ថ្ងៃព្រឹត្តិការណ៍នោះ។
- មើលកីឡាករ និងព្រឹត្តិការណ៍ហែលទឹក រួចហើយយាយអំពីពេលវេលាដែលកីឡាករសំរេចជោគជ័យនៅក្នុងព្រឹត្តិការណ៍នោះ។
- សម្គាល់រកថ្ងៃ "ផុតកំណត់" នៅពីលើឥវ៉ាន់ទិញមកពីផ្សារហើយពិភាក្សាអំពីចំនួនថ្ងៃដែលនៅសល់ដើម្បីប្រើរបស់ទាំងនោះ។
- ឲ្យកូនរបស់លោកអ្នកជួយលោកអ្នកអានតារាងពេលវេលារថបាស់ និងរទេះភ្លើងធ្វើដំណើរនៅពេលប្រើយានជំនិះសាធារណៈ ឬអានតារាងចេញដំណើរ និងមកដល់ប្រសិនបើនៅអាកាសយានដ្ឋាន។
- សម្លឹងមើលសញ្ញាចតឡាន រួចហើយពិភាក្សាអំពីពេលមោ៉ងកំណត់នៅពេលចតឡាន។
- ឲ្យកូនរបស់លោកអ្នកជួយដាក់កាក់ចំនួនត្រឹមត្រូវចូលទៅក្នុងម៉ាស៊ីនចតឡាន ហើយនិយាយអំពីចំនួនពេលវេលា មុននឹងម៉ាស៊ីនចតឡានផុតកំណត់ពេលចត។
- មើលការណែនាំដែលមាននៅពីលើកញ្ចប់ម្ហូប ឬភេសជ្ជៈដើម្បីឲ្យបានដឹងអំពីកំដៅដែលត្រូវបានណែនាំសំរាប់រក្សាវាទុក។
- ប្រាប់ឲ្យកូនរបស់លោកអ្នកខ្ទប់ ហើយដាក់ផ្លាកថ្ងៃ "ផុតកំណត់" សំរាប់សាច់ ឬអាហារឆ្អិនដែលត្រូវទុកដាក់ឲ្យវាកក។

# មាតាបិតាក៏រាប់ផងដែរ



- និយាយប្រាប់កូនរបស់លោកអ្នកអំពីរបៀបដែលកំដៅនឹងផ្លាស់ប្តូរម្ហូបអាហារ និងភេសជ្ជៈក្នុងកាលលោកអ្នកកំពុងដាំស្ល។ *តើនឹងមានអ្វីកើតឡើងនៅពេលដាក់ទឹកចូលទៅក្នុងម៉ាស៊ីនធ្វើឲ្យកក? តើឃើញអ្វីកើតឡើងឬទេ នៅពេលណាខ្ញុំដាក់នំឆ្អូកូឡេតចូលទៅក្នុងឆ្នាំងខ្ទះដែលក្តៅនៅពីលើចង្ក្រាន។*
- មើលការនិយាយប្រាប់អាកាសធាតុជាមួយគ្នា រួចហើយនិយាយអំពីកំដៅដែលត្រូវបានគេទាយទុក។ សួរកូនរបស់លោកអ្នក ថាតើគេនឹងត្រូវការអ្វីដើម្បីស្លៀកពាក់ ឬយកតាមជាប់ជាមួយគេ។
- មើលដើមឈើដែលមាននៅជុំវិញតំបន់ជិតខាងរបស់លោកអ្នក ហើយនិយាយអំពីរបៀបដែលដើមឈើផ្លាស់ប្តូរទៅតាមរដូវ។
- រកមើលប្រភេទខុសគ្នានៃប្រដាប់ស្ទង់មើលកំដៅ ហើយនិយាយអំពីរបៀបប្រើវា។
- វាស់មើលកំដៅនៃទឹកក្នុងអាងងូតទឹក មុននឹងកូនរបស់លោកអ្នកឈានជើងចូលទៅក្នុងអាងទឹកនោះ។ និយាយអំពីទឹកដែលក្តៅខ្លាំង ឬទឹកត្រជាក់ខ្លាំង ឬកំដៅត្រឹមត្រូវសំរាប់ងូត។
- និយាយអំពីបញ្ហានិរភ័យទាំងឡាយទាក់ទិននឹងរបស់ប្រើប្រាស់ក្នុងផ្ទះ ដែលអាចក្តៅខ្លាំងដូចជាចង្ក្រានដាំស្ល ឆ្នាំងអ៊ុត ឬម៉ាស៊ីនកំដៅ។
- ចែករំលែកសៀវភៅដែលសរសេរអំពីកំដៅ ឬរដូវ។ ព្រឹត្តិការណ៍ ឬពិធីបុណ្យល្បីៗដូចជាបុណ្យគ្រីស្តម៉ាស្ត អាចយកទៅប្រៀបធៀបទៅនឹងព្រឹត្តិការណ៍ដូចគ្នានៅក្នុងប្រទេសដែលមានធាតុអាកាសត្រជាក់។


Curriculum K–12 Directorate, © NSW Department of Education